

## ពតិមានស្តីពីការសុំឈប់សំរាករយៈពេលខ្លី ដោយសារមូលហេតុគ្រួសារ ដែលនៅ ទទួលបានប្រាក់កំរៃ

- ផ្តល់នូវអត្ថប្រយោជន៏ តែមិនផ្តល់នូវសុវត្ថិភាពការងារ រឺក៏សិទ្ធិត្រឡប់មកធ្វើការវិញ
- ផ្តល់អោយបុគ្គលិកដែលមានសិទ្ធិនូវសំណងប្រាក់កំរៃ មួយចំនួន នៅពេលដែលសុំច្បាប់ឈប់សំរាក ដើម្បី ទៅថែទាំឪពុកម្តាយ កូនៗ ប្តីឬប្រពន្ធ និងគូស្នេហ៍ ស្របច្បាប់ ឬ ដើម្បីជួបជុំជាមួយកូនតូចដែលទើបនឹងកើត
- ធានារ៉ាបរងរាល់បុគ្គលិកទាំងអស់ ដែលទទួល ធការធានារ៉ាប់រងដោយSDI (ឬក៏គំរោងស្ម័គ្រចិត្ត ជំនួសដោយកម្មវិធី SDI)
- ផ្តល់នូវអត្ថប្រយោជន៏រហូតដល់ 6 សប្តាហ៍ ក្នុងកំឡុងពេល12ខែ
- ផ្តល់អត្ថប្រយោជន៏ប្រហែលជា 55% នៃប្រាក់កំរៃ ដែលបាត់បង់

នៅរដ្ឋកាលីហ្វ័ញ៉ា វាគឺជាច្បាប់ ។

# ការឈប់សំរាកដោយសារមូលហេតុ គ្រួសារ ដែលនៅតែទទួលបានប្រាក់កំរៃ

កម្មវិធីធានារ៉ាប់រង

ពេលដែលត្រូវផ្តល់ការយកចិត្តទុកដាក់គឺ 1-877-238-4373

សំរាប់ពតិមានបន្ថែម សូមបើកមើលវិបសាយ:

**www.edd.ca.gov**

1-877-238-4373 (ភាសាអង់គ្លេស)
1-877-379-3819 (ភាសាអេសស្បាញ)
1-866-692-5595 (ភាសាចិនកាតាំង)
1-866-692-5596 (ភាសាវៀតណាម)
1-866-627-1567 (ភាសា Armenian)
1-866-627-1568 (ភាសា Punjabi)
1-866-627-1569 (ភាសា Tagalog)
1-800-445-1312 (TTY)

EDD គឺជានិយោជករឺ កម្មវិធីដែលផ្តល់ឱកាសស្មើៗគ្នា ។ជំនួយ និងសេវាបន្ថែម អាចរកបានទៅតាមសំណើរបស់ជនពិការ ។សំណើរ សុំសេវា ជំនួយ និង / រឺ ទំរង់ជ្រើសរើសផ្សេងៗត្រូវធ្វើឡើងដោយ ទូរស័ព្ទមកលេខ

877-238-4373 (ជាសំលេង) រឺ TTY 800-445-1312 ។

កូនសៀវភៅតូចនេះគឺសំរាប់តែពតិមានទូទៅ ប៉ុណ្ណោះ ហើយមិនមានអំណាច និងឥទ្ធិពលរបស់ច្បាប់ វិន័យ រឺ បទបញ្ជាទេ ។

រដ្ឋកាលីហ្វ័ញ៉ា

EDD Employment Development Department
State of California



# ពេលដែលអ្នកត្រូវការពេលវេលាបែបនេះ ។

កម្មវិធីធានារ៉ាប់រងសំរាប់ការឈប់សំរាកដោយសារមូលហេតុគ្រួសារ ដែលនៅតែទទួលបានប្រាក់កំរៃ ។



# អត្ថប្រយោជន៍ធានារ៉ាប់រងទៅលើ ការសុំឈប់សំរាករយៈពេលខ្លី ដោយសារ មូលហេតុគ្រួសារ ដែលនៅទទួលបានប្រាក់កំរៃ សំរាប់និយោជិកនៃរដ្ឋកាលីហ្វ័ញ៉ា

**មានពេលជាច្រើននៅក្នុងជីវិតរបស់អ្នកធ្វើការគ្រប់រូប ដែលពួកគេ ត្រូវថែទាំអ្នកដែលគេស្រលាញ់។ អាចជាមាតា ដែលធ្វើការ ដែលត្រូវការពេលច្រើនដើម្បីនៅជាមួយទារកទើបនឹងកើត ។ ប្រហែលមាតាជាអ្នកធ្វើការម្នាក់ ដែលត្រូវការពេលច្រើនថែមទៀតដើម្បីនៅជាមួយទារកទើបនឹងកើត ។ អត្ថប្រយោជន៍ធានារ៉ាប់រង ទៅលើ ការសុំឈប់សំរាករយៈពេលខ្លី ដោយសារមូលហេតុគ្រួសារ ដែលនៅទទួលបានប្រាក់កំរៃរបស់រដ្ឋកាលីហ្វ័ញ៉ា ត្រូវបានបង្កើតឡើង សំរាប់ពេលបែបនេះ ។ កំណត់សំគាល់: គូស្នេហ៍ស្របច្បាប់ត្រូវតែ បំពេញតាមល័ក្ខខ័ណ្ឌ ហើយបានចុះឈ្មោះនៅរដ្ឋលេខាធិការដ្ឋាន នៃរដ្ឋកាលីហ្វ័ញ៉ា ដើម្បីមានសិទ្ធិទទួលបានអត្ថប្រយោជន៍) ។**



# កម្មវិធីដែលផ្តល់អត្ថប្រយោជន៍ដល់អ្នក និងគ្រួសាររបស់អ្នក

California គឺកំពុងតែដឹកនាំជាតិក្នុងនាមជារដ្ឋដំបូង ដើម្បីធ្វើអោយ មានលក្ខណៈងាយស្រួលដល់និយោជិកក្នុងការថ្លឹងថ្លែងនូវតំរូវការ របស់កន្លែងធ្វើការ និងតំរូវការថែទាំគ្រួសារនៅផ្ទះ ។ អត្ថប្រយោជន៍ ធានារ៉ាប់រង ទៅលើការសុំឈប់សំរាករយៈពេលខ្លី ដោយសារ មូលហេតុគ្រួសារ ដែលនៅទទួលបានប្រាក់កំរៃ គឺអាស្រ័យទៅលើ ប្រាក់ចំណូលប្រចាំត្រីមាសពីមុនរបស់បុគ្គលដែលទាមទារ អ្នកផ្តល់ ការថែទាំ) ហើយមានចំនួនអប្បបរិមាពី 50 ដុល្លា ទៅអតិបរិមា917 ដុល្លា ក្នុងមួយសប្តាហ៍ ដែលនឹងផ្តល់ជូនរហូតដល់ 6សប្តាហ៍ ។

# ការសុំឈប់សំរាករយៈពេលខ្លី ដោយសារ មូលហេតុគ្រួសារ ដែលនៅទទួលបានប្រាក់កំរៃ សំរាប់និយោជិកនៃរដ្ឋកាលីហ្វ័ញ៉ា

ការធានារ៉ាប់រងទៅលើការសុំឈប់សំរាករយៈពេលខ្លីដោយសារមូលហេតុ គ្រួសារដែលនៅតែទទួលបានប្រាក់កំរៃ មិនផ្តល់នូវសុវត្ថិភាពការងារ រឺសិទ្ធិ ត្រឡប់មកធ្វើការវិញទេ ។ ការងាររបស់អ្នកអាច ត្រូវបានការពារ ប្រសិនបើ និយោជករបស់អ្នកគោរពតាមច្បាប់សហព័ន្ធស្តីពីការសុំឈប់សំរាករយៈពេល ខ្លី ដោយសារមូលហេតុថែទាំគ្រួសារ និងច្បាប់ស្តីពីសិទ្ធិគ្រួសាររបស់ រដ្ឋកាលីហ្វ័ញ៉ា ។ អ្នកត្រូវតែបញ្ជាក់ពីហេតុផលរបស់អ្នក ដល់និយោជក ដើម្បីសុំឈប់សំរាក ដោយគោរពទៅតាម គោលការណ៏នៃការសុំឈប់សំរាក របស់ក្រុមហ៊ុន ។

ដើម្បីអាចទទួលបានអត្ថប្រយោជន៏ធានារ៉ាបរងទៅលើការសុំឈប់សំរាក រយៈពេលខ្លី ដោយសារមូលហេតុគ្រួសារដែលនៅតែទទួលបានប្រាក់កំរៃ អ្នកត្រូវបំពេញទៅតាមតំរូវការដូចខាងក្រោម:

- ត្រូវបានធានាដោយការធានារ៉ាប់រងរបស់រដ្ឋទៅលើភាពអសម្កភាព (SDI) (រឺកំគំរោងស្ម័គ្រចិត្តជំនួសអោយ SDI) ហើយរកចំណូលបាន យ៉ាងហោច ណាស់300 ដុល្លា នៅក្នុងកំឡុងពេលដំបូង ក្រោយពីបង់ពន្ធរួចហើយ
- បំពេញបែបបទទាមទារអោយបានត្រឹមត្រូវ អោយបានចប់សព្វគ្រប់ ដោយទៀងត្រង់ និងទាន់ពេលវេលា
- បញ្ជូនពាក្យសុំទាមទាររបស់អ្នក កុំអោយលឿនជាង 9 ថ្ងៃ ប៉ុន្តែ កុំអោយ យឺតជាង 49 ថ្ងៃ បន្ទាប់ពីថ្ងៃដំបូងនៃការសុំឈប់ទៅថែទាំគ្រួសារចាប់ផ្តើម
- ផ្តល់នូវពត៌មានវេជ្ជសាស្ត្រដែលគាំទ្រដល់ការទាមទាររបស់អ្នក ដែលថា អ្នកដែលត្រូវទទួលការថែទាំមានល័ក្ខខ័ណ្ឌសុខភាពធន់ធរ ហើយត្រូវការ ការថែទាំរបស់អ្នក
- ផ្តល់នូវឯកសារគាំទ្រដល់ការទាមទារដើម្បីនៅមើលថែទាំកូនបង្កើត កូនយកមកចិញ្ចឹមស្របច្បាប់ រឺកូនចិញ្ចឹមមិនស្របច្បាប់ ។
- ប្រើការសុំច្បាប់ឈប់សំរាកពីការធ្វើការធម្មតារហូតដល់ទៅ ពីរ សប្តាហ៍ ប៉ុន្តែមិនប្រើការសុំច្បាប់ឈប់លំហែកាយ រឺការឈប់សំរាក ដែលទទួលបានប្រាក់កំរៃ (PTO) ប្រសិនបើមានការតំរូវដោយ និយោជករបស់អ្នក មុនពេលទទួលបាននូវអត្ថប្រយោជន
- បំរើការងារដោយមិនទទួលបានប្រាក់កំរៃ 7 ថ្ងៃក្នុងកំឡុងពេលរង់ចាំ មុននឹងចាប់ផ្តើមទទួលនូវអត្ថប្រយោជន៏ សំរាប់រាល់អ្នកដែលត្រូវ ទទួលការថែទាំនិមួយៗ ក្នុងកំឡុងពេល 12 ខែ

អ្នកអាចនឹងមិនមានសិទ្ធិទទួលបានអត្ថប្រយោជន៏ ប្រសិនបើ :

- អ្នកទទួលបាននូវការធានារ៉ាប់រងរបស់រដ្ឋទៅលើភាពអសមត្ថភាព (SDI) ការធានារ៉ាប់រងទៅលើភាពឥតការងារធ្វើ រឺការទូរទាត់សងរបស់និយោជិក អ្នកមិនកំពុងតែធ្វើការ រឺមិនកំពុងតែរកការងារធ្វើ នៅពេលដែលអ្នក ចាប់ផ្តើមការឈប់សំរាកមើលថែទាំគ្រួសាររបស់អ្នក
- អ្នកមិនទទួលរងនូវការបាត់បង់ប្រាក់កំរៃ
- តំរូវការការថែទាំគឺមិនត្រូវបានគាំទ្រដោយលិខិតបញ្ជាក់របស់ គ្រូពេទ្យព្យាបាលជំងឺ ឬ វេជ្ជបណ្ឌិតនោះទេ
- អ្នកត្រូវថិតនៅក្នុងការឃុំឃាំងដោយសារការផ្តន្ទាទោសពីការប្រព្រឹត្តិ បទឧក្រិដ្ឋ



អ្នកមានសិទ្ធិ:

- ដឹងពីហេតុផល ហើយមូលដ្ឋាននៃការសំរេចចិត្តនានា ដែលប៉ះពាល់ ដល់អត្ថប្រយោជន៏របស់អ្នក
- ប្តឹងតវ៉ានូវរាល់ការសំរេចចិត្តអំពីសិទ្ធិអាចទទួលបានអត្ថប្រយោជន៏ របស់អ្នក ។(ការប្តឹងតវ៉ាត្រូវតែផ្ញើរទៅ Paid Family Leave ជាលាយល័ក្ខណ៏អក្សរ) ។
- ដឹងលឺអំពីការប្តឹងតវ៉ារបស់អ្នក មុនចៅក្រមច្បាប់រដ្ឋបាល (ALJ) ។ អ្នកអាចបន្តប្តឹងការសំរេចរបស់ ALJ ទៅក្រុមប្រឹក្សាបណ្តឹងទៅលើការធានារ៉ាប់រង លើភាពឥតការធ្វើ នៃរដ្ឋកាលីហ្វ័ញ៉ា និងប្តឹងទៅតុលាការ ។
- ទទួលបាននូវការរក្សាទុកជាសំងាត់ មានន័យថាពត៌មានអំពីការទាមទាររបស់អ្នក នឹងត្រូវបានរក្សាទុកជាសំងាត់ លើកលែងតែក្នុងករណីដែលមានការទាមទារ ដោយច្បាប់

# ទំនាក់ទំនងមកកាន់កម្មវិធីឈប់សំរាករយៈពេលខ្លីដោយ មូលហេតុគ្រួសារដែលនៅទទួលបានប្រាក់កំរៃ

ប្រសិនបើអ្នកមានសំណួរផ្សេងៗអំពីអត្ថប្រយោជន៏ទាំងនេះ រឺចង់ស្នើសុំ បែបបទ ទាមទារ សូមទំនាក់ទំនងយើងនៅថ្ងៃនេះ ។ ប្រសិនបើអ្នកជាស្ត្រី ដែលបច្ចុប្បន្នកំពុង តែទទួលបាននូវអត្ថប្រយោជន៏ SDI ដែលទាក់ទងនឹងការមានផ្ទៃពោះ វាមិនចាំបាច់ ស្នើសុំការទាមទារសំរាប់អត្ថប្រយោជន៏ឈប់សំរាករយៈពេលខ្លីដោយសារមូលហេតុ គ្រួសារ ដែលនៅទទួលបានប្រាក់កំរៃនោះទេ ។ អ្នកនឹងត្រូវបានគេផ្ញើរបែបបទ ទាមទារសុំអត្ថប្រយោជន៏នៃការឈប់សំរាករយៈពេលខ្លី ដោយសារមូលហេតុគ្រួសារ ដែលនៅទទួលបានប្រាក់កំរៃ (PFL) ដោយស្វ័យប្រវត្តិ វាគឺជា New Mother, DE 2501FP នៅពេលដែល ការទាមទារទៅលើភាពអសមត្ថភាពនៅពេលមានផ្ទៃពោះ ត្រូវបានបញ្ចប់ ។

**1-877-238-4373**(ភាសាអង់គ្លេស) **1-877-379-3819**(ភាសាអេសប៉្សាញ)

**1-866-692-5595**(ភាសាចិនកាតាំង) **1-866-692-5596**(ភាសាវៀតណាម)

**1-866-627-1567**(ភាសា **Armenian**) **1-866-627-1568**(ភាសា **Punjabi**)

**1-866-627-1569**(ភាសា **Tagalog**) **1-800-445-1312 (TTY)**

សំរាប់ពត៌មានបន្ថែម សូមបើកមើលវិបសាយ : **www.edd.ca.gov**

បែបបទទាមទារគួរតែផ្ញើរទៅ Paid Family Leave ដែលមានអាស័យដ្ឋាន:
P.O. Box 997017, Sacramento, CA 95799-7017